# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**


ក្រសួងពាណិជ្ជកម្ម
Ministry of Commerce


លេខ ១២៥ ព.ណ. កសប.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញប្រកាសលេខ ២០៦ ពណ.បអ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- បានឃើញប្រកាសលេខ ២៩៣ ពណ.កសប.ប្រក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួង ពាណិជ្ជកម្ម ស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកវិញ្ញាតកម្ម
- បានឃើញប្រកាសលេខ ៣៦៨ ពណ.កសប.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

- បានឃើញប្រកាសលេខ ៤២២ ពណ.កសប.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ។

## សម្រេច

### ប្រការ ១.-គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក តាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈគេហទំព័រ www.efiling.cambodiaip.gov.kh ។

### ប្រការ ២.-គោលដៅ

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនិងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក
- គាំទ្រដល់ការផ្តល់សេវាចុះបញ្ជីម៉ាកឲ្យបានកាន់តែល្អប្រសើរឡើង
- សម្រួលដល់ការគ្រប់គ្រងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងម៉ាក
- គ្រប់គ្រងការផ្តល់លិខិត និងឯកសារពាក់ព័ន្ធផ្សេងៗ
- គ្រប់គ្រងការប្រមូលកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងកិច្ចការពារម៉ាកឲ្យបានកាន់តែមានប្រសិទ្ធភាពថែមទៀត ។

### ប្រការ ៣.-វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តលើការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ប្រការ ៤.- វាក្យសព្ទ

សម្រាប់គោលដៅនៃប្រកាសនេះ៖

"ម៉ាក" សំដៅដល់ ម៉ាក ម៉ាកសមូហភាព ពាណិជ្ជនាម ម៉ាកវិញ្ញាបនកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រ។

"ប្រព័ន្ធអេឡិចត្រូនិក" សំដៅដល់ប្រព័ន្ធដែលរៀបចំឡើងសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមអេឡិចត្រូនិក ។

"អ្នកដាក់ពាក្យស្នើសុំ" សំដៅដល់ អ្នកស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក តាមប្រព័ន្ធអេឡិចត្រូនិក ។

### ប្រការ ៥.-បទប្បញ្ញត្តិដែលអាចអនុវត្តបាន

បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ នៃច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាដែលអាចអនុវត្តបាន ត្រូវយកមកអនុវត្តផងដែរចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ។

## ប្រការ ៦.-សមត្ថកិច្ចគ្រប់គ្រង

នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម មានសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធអេឡិចត្រូនិក ការទទួលពាក្យស្នើសុំសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក និងការផ្តល់ឈ្មោះគណនី និងលេខកូដសម្ងាត់សម្រាប់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ។

## ប្រការ ៧.-អ្នកដាក់ពាក្យស្នើសុំ

អ្នកដាក់ពាក្យស្នើសុំដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្ម ស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ។

អ្នកដាក់ពាក្យស្នើសុំដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្ម ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ការស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិកត្រូវធ្វើឡើងដោយភ្នាក់ងារតំណាងស្របច្បាប់ដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងដែលដាក់ពាក្យស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវភ្ជាប់មកជាមួយឯកសារតម្រូវ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាទម្រង់អេឡិចត្រូនិក ។

អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងត្រូវធានាថា រាល់ឯកសារតម្រូវភ្ជាប់ជាទម្រង់អេឡិចត្រូនិកដែលផ្តល់មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ជាឯកសារពិត និងឥតក្លែងបន្លំ ។

ជនណាដែលផ្តល់ព័ត៌មានមិនពិត ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងច្បាប់ពាក់ព័ន្ធជាធរមាន ។

## ប្រការ ៨.-ការដាក់ពាក្យស្នើសុំ

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក តម្រូវឲ្យមានឈ្មោះគណនី និងលេខកូដសម្ងាត់ ដែលកំណត់ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។

ក្រោយការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឯកសារតម្រូវជាទម្រង់ច្បាប់ដើម ឬទម្រង់ច្បាប់ចម្លងដោយមានបញ្ជាក់ពីភាពត្រឹមត្រូវ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម តាមកាលកំណត់ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

## ប្រការ ៩.-កម្រៃសេវា

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបង់កម្រៃសេវាតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារ ដោយអនុលោមតាមប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតជាធរមាន ឬលិខិតបទដ្ឋានគតិយុត្តដែលនឹងត្រូវបានធ្វើវិសោធនកម្ម ។

**ប្រការ ១០.-ប្រសិទ្ធភាពអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន់_សូរស័ក្តិ**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។